## ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៣៣...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និង សេវាសុខាភិបាលខុសច្បាប់ដើម្បីកាត់បន្ថយភាពក្រីក្រ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីបែបបទ និងល័ក្ខខ័ណ្ឌនៃការអនុញ្ញាតអោយជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការមួយដែលមានឈ្មោះ គណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដែលមានវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជាសម្រាប់កាត់បន្ថយភាពក្រីក្រ ។

គណៈកម្មាធិការមានគណៈកម្មការ២ ÷

**១.១ គណៈកម្មការអន្តរក្រសួង**

គណៈកម្មការអន្តរក្រសួងមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូបជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣. អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១ រូបជាអនុប្រធាន |
| ៤. អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១ រូបជាអនុប្រធាន |
| ៥. អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ០១ រូបជាសមាជិក |
| ៦. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | ០១ រូបជាសមាជិក |
| ៧. អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ០១ រូបជាសមាជិក |
| ៨. អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូបជាសមាជិក |
| ៩. អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូបជាសមាជិក |
| ១០.អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១ រូបជាសមាជិក |
| ១១.អភិបាលរងរាជធានីភ្នំពេញ | ០១ រូបជាសមាជិក |
| ១២.ប្រធាននាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល | ជាសមាជិក |
| ១៣.ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង នៃក្រសួងសុខាភិបាល | ជាលេខាធិការ |

**១.២ គណៈកម្មការខេត្ត-ក្រុង**

គណៈកម្មការខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១. អភិបាលរងខេត្ត ក្រុង | ជាប្រធាន |
| ២. ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៣. អនុប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង | ០១ រូបជាសមាជិក |

| | |
|---|---|
| ៤. តំណាងអយ្យការតុលាការខេត្ត ក្រុង | ០១ រូបជាសមាជិក |
| ៥. ស្នងការនគរបាលខេត្ត ក្រុង | ជាសមាជិក |
| ៦. ប្រធានមន្ទីរព័ត៌មានខេត្ត ក្រុង | ជាសមាជិក |
| ៧. ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ក្រុង | ជាសមាជិក |
| ៨. ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង | ជាសមាជិក |
| ៩. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង | ជាសមាជិក |
| ១០.ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង | ជាសមាជិក |
| ១១.ប្រធានសាខាកាំកុងត្រូលខេត្ត ក្រុង | ជាសមាជិក |
| ១២.ប្រធានការិយាល័យបច្ចេកទេសនៃមន្ទីរសុខាភិបាល | ជាសមាជិក |
| ១៣.ប្រធានការិយាល័យឱសថ និងសុវត្ថិភាពចំណីអាហារ | ជាលេខាធិការ |

**ប្រការ ២.-**

គណៈកម្មាធិការលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង និងអន្តរជាតិដើម្បីលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ដែលបច្ចុប្បន្នកំពុងកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា
- ខិតខំស្វែងរកប្រភពនៃឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- ចាត់វិធានការប្រកបដោយប្រសិទ្ធភាពក្នុងការត្រួតពិនិត្យជាប្រចាំដើម្បីឃាត់ទុក បំផ្លាញចោល និងទប់ស្កាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ឈានទៅលុបបំបាត់ជាស្ថាពរ
- ផ្សព្វផ្សាយ អប់រំ និងលើកកម្ពស់ការយល់ដឹងដល់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់
- រៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីវិនិច្ឆ័យទោសតាមច្បាប់ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើស ។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាលដើម្បីសម្រួលការងារ ។

គណៈកម្មការខេត្ត ក្រុង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ដើម្បីសម្រួលការងារ ។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានលេខាធិការដ្ឋាននៅក្រសួងសុខាភិបាល ។

គណៈកម្មការខេត្ត ក្រុង លុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់សម្រាប់កាត់បន្ថយភាពក្រីក្រ មានលេខាធិការដ្ឋាននៅមន្ទីរសុខាភិបាលខេត្ត ក្រុង ។

**ប្រការ ៥.-**

បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង និងសមាជិកគណៈកម្មការខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានដើម្បីរាយការណ៍ពីសកម្មភាព និងលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៦.-**

រាល់ចំណាយរបស់គណៈកម្មាធិការជាបន្ទុករបស់ក្រសួងសុខាភិបាល ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងសមាសភាព ដូចក្នុងប្រការ១ខាងលើនេះ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គ្រប់ ក្រសួង ស្ថាប័ន
- -ដូចប្រការ១
- -ឯកសារ កាលប្បវត្តិ